ការចេញផ្សាយព័ត៌មានថ្មីៗ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩

# យុទ្ធនាការថ្មីស្ដីពីសុវត្ថិភាពតាមអនឡាញ ដើម្បីជួយចាប់ផ្ដើមការជជែក

ថ្ងៃនេះ ក្នុងទិវាវិធានការជាតិប្រឆាំងនឹងការសម្លុតធ្វើបាប និងអំពើហិង្សា យុទ្ធនាការថ្មីមួយត្រូវបានចាប់ផ្ដើម ដើម្បីជួយដល់ឪពុកម្ដាយ អ្នកថែទាំ និងគ្រូបង្រៀនដើម្បីចាប់ផ្ដើមជជែកអំពីសុវត្ថិភាពតាមអនឡាញ។

ការស្រាវជ្រាវបង្ហាញថា កុមារអូស្ត្រាលីច្រើនជាងពេលណាទាំងអស់កំពុងទទួលបទពិសោធន៍អវិជ្ជមានតាមអនឡាញ រួមមានការសម្លុតធ្វើបាបតាមអនឡាញ ការធ្វើទំនាក់ទំនងដែលមិនចង់បានពីមនុស្សចម្លែក និងការដកខ្លួនចេញពីសង្គមមនុស្ស។

យុទ្ធនាការថ្នាក់ជាតិនេះមានគោលបំណងផ្ដត់ផ្ដង់ឪពុកម្ដាយ អ្នកថែទាំ និងគ្រូបង្រៀននូវធនធានត្រឹមត្រូវដើម្បីជួយរក្សាកុមារ និងយុវវ័យឱ្យមានសុវត្ថិភាពតាមអនឡាញ។

"ការស្រាវជ្រាវរបស់យើងបង្ហាញថា ឪពុកម្ដាយចំនួន៨១ភាគរយ បានផ្ដល់ឱ្យកូនរៀនថ្នាក់មត្តេយ្យរបស់ពួកគេប្រើប្រាស់ឧបករណ៍តភ្ជាប់អ៊ិនធើណិត ដូច្នេះការសន្ទនាដោយបើកចំហ និងស្មោះត្រង់អំពីឥរិយាបថតាមអនឡាញដែលមានសុវត្ថិភាព ចាំបាច់ត្រូវចាប់ផ្ដើមពីក្នុងផ្ទះឆាប់ជាងមនុស្សភាគច្រើនគិតឃើញទៅទៀត" នេះបើតាមសម្ដីរបស់លោកស្រី Julie Inman Grant ស្នងការ eSafety។

"ជាមួយនឹងបច្ចេកវិទ្យាដែលមានការផ្លាស់ប្ដូរយ៉ាងលឿន វាជាការសំខាន់ខ្លាំងណាស់ដែលឪពុកម្ដាយ គ្រូបង្រៀន និងអស់អ្នកមើលថែកុមារត្រូវបានបំពាក់ជាមួយនឹងព័ត៌មានទាន់បច្ចុប្បន្នភាពដែលត្រឹមត្រូវ និងងាយស្រួលតាមដាន។ តាមវិធីនេះ យើងទាំងអស់គ្នាអាចដើរតួក្នុងការធានាឱ្យកុមារមានសុវត្ថិភាព និងបទពិសោធន៍វិជ្ជមានតាមអ៊ីនធើណិត" លោកស្រី Inman Grant មានប្រសាសន៍។

តាមរយៈធនធានជាច្រើនដែលមាននៅតាម [វិបសៃថ៍] របស់ eSafety ឪពុកម្ដាយ អ្នកថែទាំ និងគ្រូបង្រៀនអាចស្វែងរកព័ត៌មានអំពីផលវិបាកផ្ទាល់ខ្លួន និងអារម្មណ៍ - ហើយក្នុងករណីខ្លះទៀត ខាងផ្លូវច្បាប់ ដែលបណ្ដាលមកពីឥរិយាបថតាមអនឡាញ។

លោកស្រី Inman Grant មានប្រសាសន៍ថា "ថ្ងៃនេះ ក្នុងទិវាវិធានការជាតិការប្រឆាំងនឹងការសម្លុតធ្វើបាប និងអំពើហិង្សា វិធីល្អបំផុតមួយដែលយើងអាចចាត់វិធានការ គឺចាប់ផ្ដើមការសន្ទនាជាមួយកូនៗរបស់យើង"។

សិស្សជាងពីរលាននាក់ មកពីសាលារៀនជាង៥០០០ ពេញទូទាំងប្រទេសអូស្ត្រាលីកំពុងនិយាយថា 'ការសម្លុតធ្វើបាប។ គឺគ្មានកន្លែងទាល់តែសោះ' ដែលជាផ្នែកមួយនៃទិវាវិធានការជាតិប្រឆាំងនឹងការសម្លុតធ្វើបាប និងអំពើហិង្សា។

ទិវាវិធានការជាតិប្រចាំឆ្នាំទី៩ លើកទឹកចិត្តសិស្ស គ្រូបង្រៀន និងឪពុកម្ដាយ ឱ្យប្រកាន់ជំហរប្រឆាំងនឹងការសម្លុតធ្វើបាប និងអំពើហិង្សានៅតាមសាលារៀនរបស់យើង។

លោកស្រី Inman Grant មានប្រសាសន៍ថា "ការសម្លុតធ្វើបាបតាមអនឡាញ អាចមានទម្រង់ជាច្រើនដូចជាការជេរប្រមាថឈ្មោះសារដែលមិនចង់បាន ក៏ដូចជាការគំរាមកំហែង និងខ្លឹមសារដែលបានបង្ហោះដោយគ្មានការយល់ព្រម - ហើយថ្ងៃនេះ យើងកំពុងផ្ញើសារដ៏រឹងមាំថា វាមិនដែលអត់អីនោះទេ"។

eSafety កំពុងរៀបចំ [ថ្នាក់រៀនជាក់ស្ដែង] ដោយឥតគិតថ្លៃ សម្រាប់សាលារៀននៅទូទាំងប្រទេស ដើម្បីជួយពង្រឹងកម្លាំងដល់សិស្ស និងគ្រូបង្រៀន តាមរយៈយុទ្ធសាស្ត្រជាក់ស្ដែងដើម្បីទប់ស្កាត់ គ្រប់គ្រង និងរាយការណ៍ពីការសម្លុតធ្វើបាបតាមអនឡាញ។

សិស្សជាង៣២០,០០០នាក់បានចូលរួមនៅក្នុងថ្នាក់រៀនទាំងនេះ ចាប់តាំងពីឆ្នាំ២០១៥។

ឪពុកម្ដាយ អ្នកថែទាំ គ្រូបង្រៀន និងអ្នកផ្សេងទៀតអាចស្វែងរកព័ត៌មានបន្ថែមនៅត្រង់វិបសៃថ៍ esafety.gov.au។

សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីរៀបចំការសម្ភាសន៍ សូមទាក់ទង: **Paula Masselos** នៅ **Embrace Society** ទូរស័ព្ទលេខ 02 8090 7737 និង 0419 292 207 ឬអ៊ីម៉ែល paula@embracesociety.com.au